00819468

002/19-09-2007-ECCC/TC
E1/86

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
~~Nation Religion Roi~~

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 06 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៧៤

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Matteo CRIPPA, លោកស្រី Natacha WEXELS-RISER, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ាត់, លោក Tarik ABDULHAK, លោក Keith RAYNOR |

| |
|---|
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMEN |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក គីម ម៉េងឃី, លោកស្រី ទី ស្រីនណា, លោក សំ សុគង់, លោក Barnabé NEKUIE. |
| សាក្សី៖ លោក អឿន តាន (TCW-488) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA, លោក សេង រិទ្ធី (មេធាវីប្រឹក្សាសាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០០<br>១២.០០ | ០៩.០០<br>១២.០០ |
| សំណើសុំឲ្យធ្វើការបញ្ជាក់អំពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៥<br>០៩.១២ | ០៩.០៧<br>០៩.១៣ |
| ការសួរបញ្ជាក់អំពីសំណើសុំជាលាយលក្ខណ៍អក្សររបស់មេធាវីការពារក្តី នួន ជា | មេធាវីការពារក្តី នួន ជា | ០៩.០៧ | ០៩.១០ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅសាក្សី អឿន តាន (TCW-488) | អង្គជំនុំជម្រះ<br><br>សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ០៩.១០<br>១៥.៥៥<br>០៩.២៣<br>១៥.០២ | ០៩.២៣<br>១៦.០៥<br>១៤.៤០<br>១៥.៥៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សំណើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី (សម្រាប់រយៈពេលពេញមួយថ្ងៃ) និង នួន ជា (សម្រាប់ពេលរសៀល) តាមរយៈមេធាវីរបស់ខ្លួន បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ ។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ ។

**<u>សំណើសុំបញ្ជាក់អំពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះ</u>**

មេធាវីការពារក្តីឱ្យ អៀង សារី បានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់អំពីសេចក្តីសម្រេចទាក់ទងនឹងការប្រើប្រាស់ឯកសារសម្រាប់សួរផ្ទុញសាក្សី។ មេធាវីបានស្នើសុំការណែនាំពីអង្គជំនុំជម្រះថាតើមេធាវីការពារក្តីអាចប្រើប្រាស់សក្ខីកម្មរបស់សាក្សីសម្រាប់ ការសួរផ្ទុញទៅសាក្សី (និងចៀសវាងការសួរម្តងទៀតដែលជាបញ្ហានៃសំណួរច្រំដែល)។ មេធាវីការពារក្តីឱ្យ នួន ជា បានគាំទ្រសំណើសុំនេះ។ ដើម្បីសម្របសម្រួលនូវបញ្ហានេះ អង្គជំនុំជម្រះបានស្នើឱ្យមេធាវីការពារក្តី អៀង សារីធ្វើសំណើជាលាយលក្ខណ៍អក្សររួចផ្ញើរទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង។

**<u>ការសួរបញ្ជាក់អំពីសំណើសុំជាលាយលក្ខណ៍ អក្សររបស់មេធាវីការពារក្តី នួន ជា</u>**

មេធាវីការពារក្តី នួន ជា បានសួរបញ្ជាក់អំពីអ៊ីម៉េលដែលក្រុមលោកបានផ្ញើរទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ ទាក់ទងនឹងបញ្ជីនៃការប្រកាសផ្សាយរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង។ ប្រធានអង្គជំនុំជម្រះបានជូនដំណឹងថា អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចអំពីបញ្ហានេះក្នុងពេលសមស្របខាងមុខនេះ។

**ការតាំងសំណួរទៅសាក្សី អឿន តាន TCW-488**

អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី អឿន តាន អំពីប្រវត្តិរូប សិទ្ធិ និងករណីកិច្ចរបស់សាក្សី។ បន្ទាប់មក សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានតាំងសំណួរទៅសាក្សី។ ចុងក្រោយអង្គជំនុំជម្រះបានសួរសំណួរបន្ថែមទៀត ទៅសាក្សី អឿន តាន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/33 | D107/2 | 00231798-00231811<br>00235125-00235136<br>00235328-00235341 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អឿន តាន<br>[Surrogate Sheet] Written Record of interview of OEUN Tan<br>[Feuille remplacée] Procès verbal d'audition de OEUN Tan | P | 00231800, 00231803-04, 00231809, 00231807 | 00235127, 00235130, 00235134, 00235132-33 | 00235331, 00235333-34, 00235339, 00235337-38 |
| E3/104 | D91/9 | 00204049-00204056<br>00204057-00204065<br>00524369-00524378 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស វិ ថ្ងៃទី០៥ ១២ ២០០៧<br>[Surrogate Sheet] Written Record of Interview of Sâ Vi<br>[Feuille remplacée] Procès verbal d'audition de Sâ Vi | P | 00204053, | 00204061-62 | 00524374-75 |
| E3/342 | D288/6.68.1 | 00329596-00330129<br>00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរស ២១<br>Annex 1: Revised S-21 Prisoner List | P | Entry 3391 | Entry 3391 | Entry 3391 |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (០៩.០០) និង នួន ជា (១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់

00819472



មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ នួន ជា និងខៀវ សំផន ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២។ ដោយឡែកជនជាប់ចោទ អៀង សារី ឲ្យនាំខ្លួនមកកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ប្រសិនបើជនជាប់ចោទស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការ។

- បង្គាប់ឲ្យនាំ សាក្សី ត្រឡប់ទៅកាន់កន្លែងស្នាក់នៅ និងនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តទៅថ្ងៃ ព្រហស្បត្តិ៍ ទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ គុលទុន្ន** **Natacha WEXELS-RISER**